# សេចក្ដីផ្ដើម រឿងដ៏ធំតែមួយ

## មេរៀនទី១ ការប្រកាសព្រះគ្រីស្ទពីគម្ពីរសញ្ញាចាស់

នៅក្នុង គម្ពីរលូកា ២៤:២៥-២៧, ៤៤-៤៦ ព្រះគ្រីស្ទបានបញ្ជាក់ដល់ពួកសិស្សថា សញ្ញាចាស់ទាំងមូលអំពីទ្រង់ផ្ទាល់។ ព្រះអង្គក៏បំភ្លឺចិត្តគំនិតគេអោយយល់ពីអត្ថន័យគម្ពីរ ហើយការយល់អត្ថន័យនៃគម្ពីរនេះគឺជាការយល់ថា គម្ពីរទាំងនោះធ្វើបន្ទាល់អំពីព្រះគ្រីស្ទ ជាពិសេសការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។

នៅក្នុង ធីម៉ូថេ ទី២ ៣:១៥ លោកប៉ុលបានសរសេរថាអ្វីៗដែលមានចែងទុកនៅក្នុងព្រះគម្ពីរគឺចែងទុកមកដើម្បីដឹកនាំយើងទៅដល់ព្រះគ្រីស្ទនិងទទួលនូវសេចក្ដីសង្គ្រោះតាមរយៈទ្រង់ផង។

ព្រះគម្ពីរសញ្ញាចាស់ត្រូវបានចែងទុកសំរាប់មនុស្សដែលរស់នៅសម័យសញ្ញាចាស់ ហើយអត្ថបទនៅក្នុងសម័យនោះ មានព្រះរាជសារដែលសំខាន់សំរាប់ពួកគេនៅសម័យនោះដែរ ហើយវាពិតជាសំខាន់ណាស់ក្នុងការយល់អំពីព្រះរាជសារសំរាប់មនុស្សនៅសម័យសញ្ញាចាស់។

ទោះយ៉ាងណាក៏ដោយ នៅក្នុងសញ្ញាថ្មីលោកប៉ុលបានសរសេរនៅក្នុងគម្ពីររ៉ូម ១៥:៤ ថា *ដ្បិតអស់ទាំងសេចក្ដីដែលបានចែងទុកមកជាមុន នោះបានចែងសំរាប់នឹងបង្រៀនដល់យើង រាល់គ្នា ដើម្បីឱ្យយើងបានសេចក្ដីសង្ឃឹម ដោយសេចក្ដី អត់ធន់ និងសេចក្ដីកំសាន្តចិត្ត ដោយសារគម្ពីរ*។ នេះបង្ហាញថា គ្រប់ទាំងអស់ដែលបានចែងទុកនៅក្នុងសញ្ញាចាស់គឺមិនមែនគ្រាន់តែសំរាប់ពួកអ៊ីស្រាអែលប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៅទៀត វាក៏ត្រូវបានចែងទុកសំរាប់យើង ជាគ្រីស្ទបរិស័ទ ដើម្បីឱ្យយើងបានសេចក្ដីសង្ឃឹម ហើយដែលសេចក្ដីសង្ឃឹមនោះបានមកដោយសារព្រះគ្រីស្ទ។ ដូច្នេះយើងគួរតែកាត់ស្រាយគម្ពីរសញ្ញាចាស់ក្នុងរបៀបមួយដែលជួយយើងឲ្យឃើញ ពីរបៀបដែលព្រះគម្ពីរសញ្ញាចាស់ផ្ដល់នូវសេចក្ដីសង្ឃឹមដល់គ្រីស្ទបរិស័ទ។ មេរៀនបន្តបន្ទាប់ទៀតនេះ នឹងជួយយើងឲ្យកាត់ស្រាយគម្ពីរសញ្ញាចាស់តាមគោលការណ៍ ហើយនិងតាមគំរូរបស់អ្នកនិពន្ធនៃគម្ពីរសញ្ញាថ្មី ព្រមទាំងរបៀបដែលគេបានកាត់ស្រាយនិងអនុវត្តន៍សញ្ញាចាស់នោះដែរ។

### រឿងដ៏ធំ

ព្រះគម្ពីរបានចាប់ផ្ដើមដំបូងបង្អស់ដោយពណ៌នាអំពីការបង្កើតរបស់សព្វសារពើ ហើយបានបញ្ចប់ដោយពណ៌នាអំពីចុងបំផុតនៃរបស់ទាំងអស់ និងការបង្កបង្កើតសារជាថ្មី។ ដូច្នេះមិនមានសៀវភៅណាមួយដូចជាព្រះគម្ពីរនោះទេ។ ឥតមានសៀវភៅណាទៀតដែលបានចាប់ផ្ដើមនៅទីដំបូងបង្អស់ ហើយបានបញ្ចប់នៅទីចុងបំផុតនៃរបស់ទាំងអស់នោះទេ។ ដូច្នេះ ព្រះរាជសារនៅក្នុងព្រះគម្ពីរគឺជាផ្ទៃរឿងមួយដែលមានរយៈពេលអស់កល្បជានិច្ច ហើយទីបញ្ចប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងទីចាប់ផ្ដើម។

នៅក្នុងលោកុប្បត្តិ ១-៣ យើងតែងតែអានថា ព្រះជាម្ចាស់បានបង្កើតរបស់ទាំងអស់ ហើយរបស់ទាំងប៉ុន្មានដែលព្រះអង្គបានបង្កើតមកសុទ្ធតែល្អទាំងគ្រប់សព្វ ប៉ុន្តែមនុស្សបានបំផ្លាញវាដោយការបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ បញ្ហាទាំងអស់នៅក្នុងលោកីយ៍នេះ វាសុទ្ធតែចេញមកពីការបះបោរនេះ ប៉ុន្តែនៅថ្ងៃមួយនៅក្នុងពេលអនាគតព្រះអង្គនឹងស្ដារធ្វើរបស់សព្វសារពើនោះ ជាថ្មីហើយល្អឥតខ្ចោះឡើងវិញ។

ដូច្នេះរចនាសម្ព័ន្ធនៃព្រះគម្ពីរគឺជាផ្ទៃរឿងធំតែមួយពីដើមទៅដល់ចប់ហើយជារឿងដែលពណ៌នាអំពីការបង្កើត ទៅដល់ការបះបោរ និងការធ្លាក់ចុះរបស់មនុស្សទៅដល់ការបង្កើតសារជាថ្មីឡើងវិញ។




ដូច្នេះ បីជំពូកដំបូង និងបីជំពូកចុងក្រោយនៃព្រះគម្ពីរ ជួយផ្ដល់រចនាសម្ព័ន្ធសំរាប់ដល់ព្រះគម្ពីរទាំងមូល។ រចនាសម្ព័ន្ធ ព្រះគម្ពីរប្រៀបបីដូចជានំប៉័ងញាត់សាច់ដូច្នោះដែរ។ ធម្មតា នំប៉័ងញាត់សាច់ មានសាច់ម្សៅនំប៉័ងនៅខាងលើនិងខាងក្រោមផ្ដល់នូវរចនាសម្ព័ន្ធដើម្បីអត្ថន័យ(ជុំសាច់) ហើយក្នុងព្រះគម្ពីរមានលោកុប្បត្តិ១-៣ នៅខាងមុខ(ដើម)និង វិវរណៈ២០-២២ នៅខាងក្រោយ(ចុង)ដើម្បីផ្ដល់រចនាសម្ព័ន្ធដល់ព្រះគម្ពីរទាំងមូលដោយផ្ដល់សេចក្ដីផ្ដើមនិងសេចក្ដីបញ្ចប់នៃសាច់រឿងតែមួយដែលឆ្លងកាត់ព្រះគម្ពីរទាំងមូល ហើយជួយបង្ហាញពីដំណើរនៃសាច់រឿងនោះផង។

## អនុវត្តន៍សំរាប់ការអានព្រះគម្ពីរ

គ្រីស្ទបរិស័ទភាគច្រើនបានដឹងហើយអំពីការបង្កបង្កើតនិងការបះបោរនៅក្នុងលោកុប្បត្តិ ១-៣ ហើយការយាងត្រលប់មកវិញរបស់ព្រះគ្រីស្ទនិងការបង្កើតថ្មីនៅក្នុងវិវរណៈ ២០-២២ ប៉ុន្តែគ្រីស្ទបរិស័ទជាច្រើនមិនយល់អំពីរបៀបដែលសេចក្តីផ្តើមនិងសេចក្តីបញ្ចប់នេះផ្តល់ការអនុវត្តន៍ចំពោះមធ្យោបាយនៃការអាន កាត់ស្រាយ និង ការអនុវត្តន៍ ព្រះគម្ពីរទាំងមូល។

ដំណើររឿងពីការបង្កបង្កើតដំបូង ទៅដល់ការបង្កើតសារជាថ្មីផ្តល់សារៈប្រយោជន៍ ចំពោះ(ដល់)ការអាន កាត់ស្រាយ និង អនុវត្តន៍គ្រប់រឿងទាំងអស់ដូចអ័ដាម កាអ៊ីននិងអេបិល ណូអេ អ័ប្រាហាំ ម៉ូសេ រ៉ាហាប ដាវីឌ ជាដើម។ល។

ព្រះគ្រីស្ទគឺជាចំនុចកណ្តាលនៃសាច់រឿងទាំងមូល ចាប់ពីសេចក្តីផ្តើមរហូតដល់សេចក្តីបញ្ចប់ របស់សព្វសារពើសុទ្ធតែកើត ឡើងដោយសារព្រះគ្រីស្ទ (យ៉ូហាន ១:៣) ហើយការបង្កើតជាថ្មីនឹងកើតឡើងនៅពេលព្រះគ្រីស្ទយាងត្រលប់មកវិញ។ ដូច្នេះហើយ ព្រះគម្ពីរប្រៀបដូចជា club sandwich គឺជាញាត់សាច់ ដែលមានពង(សុទ្ធ),ត្រសក់,ប៉េងប៉ោះហើយនិងគ្រឿងផ្សំជាច្រើនទៀតរួមទាំងឈើចាក់ធ្មេញចាក់ទំលុះនំប៉័ងញាត់សាច់ទាំងមូល(ពីម្ខាងទៅម្ខាង)ដើម្បីផ្តល់រចនាសម្ព័ន្ធ។ នៅក្នុងការពន្យល់ដោយរូបភាពនេះព្រះគ្រីស្ទប្រៀបដូចជាឈើចាក់ធ្មេញដែលឆ្លងព្រះគម្ពីរទាំងមូល។



នៅក្នុងមេរៀនបន្ទាប់យើងនឹងរៀនលំអិតថែមទៀត ដើម្បីបង្ហាញពីសេចក្តីពិតនេះដែលមាននៅក្នុងព្រះគម្ពីរ។

## *រចនាសម្ព័ន្ធនៃព្រះគម្ពីរ*

